**ព្រះរាជាណាចក្រកម្ពុជា**

**តុលាការកំពូល** **ជាតិ សាសនា ព្រះមហាក្សត្រ**

សំណុំរឿងរដ្ឋប្បវេណី ៣៣៣*៣៣

លេខៈ ៣៨៧

ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៣ ** នាមនាមប្រជារាស្ត្រខ្មែរ**

<u>សាលដីកា</u> **តុលាការកំពូល**

លេខៈ ២៦៥ បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤

ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

១-ឯកឧត្តម **ឌិត មុន្ទី** ជាប្រធាន

២-លោក ប្រាក់ គឹមសាន ជាចៅក្រមរបាយការណ៍

៣-លោក ជីវ កេង ជាចៅក្រម

៤-លោក សោម សិរីវឌ្ឍ ជាចៅក្រម

៥-លោក យស់ សូខឿន ជាចៅក្រម

ក្រឡាបញ្ជី

លោក **ម៉ៅ សុខណ្ណា**

តំណាងមហាអយ្យការ

ឯកឧត្តម **ជួន ស៊ុនឡេង** ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ៦៧"ង" ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៤១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ **អ៊ូ ឃួន** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៦០ឆ្នាំ ជាតិខ្មែរ មុខរបរកងរាជអាវុធហត្ថចូលនិវត្តន៍ ទីលំនៅភូមិទួលតាចាន់ ឃុំព្រែកឯង ស្រុកគៀនស្វាយ ខេត្តកណ្តាល ។ ប្រពន្ធឈ្មោះយឹម សារ៉ែន មានកូន០៧នាក់-។

មានមេធាវីលោកឈី សម្បត្តិ ។

ចុងចម្លើយឈ្មោះ **ឡា ចឹន** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៦ឆ្នាំ ជាតិខ្មែរ មុខរបរពាណិជ្ជករ ទីលំនៅផ្ទះលេខ២៨០ ផ្លូវលេខ១៨២ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។

មានមេធាវីលោកហាក់ សៀកលី ។

**ចម្ងល់ចំណុចទី២** : ប្តឹងជំទាស់ការអនុវត្តន៍សាលក្រម ។

បានឃើញបណ្តឹងសាទុក្ខលេខ ២៩៤ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣ របស់ឈ្មោះ ឡា មីន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៦៧"ង"ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី២ នៃសាលដីកាដោយមូលហេតុចំណុចនេះសំរេចបដិសេធសាលក្រមរបស់តុលាការខេត្ត ។

បានឃើញបណ្តឹងសាទុក្ខលេខ ២៩៨ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៣ របស់ឈ្មោះ អ៊ូ មួន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៦៧"ង"ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី៤ និងទី ៣ នៃសាលដីកា ដោយមូលហេតុការអនុវត្តន៍សាលក្រមនេះធ្វើឱ្យចូលដីខ្លួន៥ម ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣៨៧ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៣ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី២៩-១២-២០០១ របស់ឈ្មោះអ៊ូ មួន ប្តឹងជំទាស់ការអនុវត្តសាលក្រមលេខ០១"គ",០២"គ",០៣"គ",០៤"គ",០៥"គ" ចុះថ្ងៃទី១៣-០១-៩៥ ថាជាន់នឹងសាលក្រមលេខ២៧"រ",២៨"រ" ចុះថ្ងៃទី១៣-៧-១៩៩៥ ដែលបានចូលជាស្ថាពរដូចគ្នា ដូច្នេះខ្លួនសុំឱ្យលោកព្រះរាជអាជ្ញាអនុវត្តសាលក្រមលេខ ០១,០២,០៣,០៤ និង០៥"គ" កុំឱ្យចូលក្នុងសាលក្រមលេខ ២៧"រ",២៨"រ" របស់ខ្លួនបានហើយ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៦១"ក"ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០២ របស់តុលាការខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០១ របស់ដើមចោទឈ្មោះអ៊ូមួនទុកជាត្រឹមត្រូវតាមទំរង់ តែបដិសេធចោលដោយផ្ទុយពីគតិច្បាប់ ។

២-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០២ របស់ឈ្មោះ ឡា កាយ ទុកជាមានសុពលភាពតាមច្បាប់ ។

៣-បដិសេធសាលក្រមលេខ២៧"រ",២៨"រ" ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ១៩៩៥ ចោលជាអសារបង់ ។

៤-ទទួលស្គាល់សាលក្រមលេខ០១,០២,០៣,០៤ និង០៥"គ"ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៩៥ នៅមានសុពលភាពតាមច្បាប់ដដែល ។ និងសំរេចបន្ថែមដោយមានអត្ថន័យដូចខាងក្រោម :

ប្រគល់ដីដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខរៀង ពីរ០០៦០ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩១ ដែលមានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះជៀម សៀមហេង ខាងត្បូងទល់នឹងដីឈ្មោះ

មិុល សាឯម ខាងលិចទល់ផ្លូវ,ខាងកើតទល់បឹង ឱ្យទៅឈ្មោះឡា កាយ ដែលមានឈ្មោះឡា មីន ជាតំណាងផ្ទេរសិទ្ធិចាប់ពីសាលក្រមចូលស្ថាពរតទៅ ។

៥-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន៧.០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្លឹង ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ ប្រាក់ចំណាយក្នុងកិច្ចការស៊ើបសួរ ៥.០០០៛ ប្រាក់នេះដើមចោទបានបង់រួចហើយ ។

៦-សាលក្រមនេះ ជំនុំជំរះជាសាធារណៈចំពោះមុខដើមចោទឈ្មោះអ៊ួ មួន និងចុងចម្លើយឈ្មោះឡា មីន "តំណាងផ្ទេរសិទ្ធិ" ។ បើកផ្លូវប្តឹងឧទ្ធរណ៍រយៈពេល០២ខែតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០២ របស់ឈ្មោះអ៊ួ មួន ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៦១"ក"ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០២ របស់តុលាការខេត្តកណ្តាល ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៦៧"ង"ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៤-១០-២០០២ របស់ឈ្មោះអ៊ួ មួន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ៦១"ក" ចុះថ្ងៃទី២០-៨-២០០២របស់តុលាការខេត្តកណ្តាលចោលជាអសារបង់ ។

៣-បង្គាប់ឱ្យអនុវត្តន៍សាលក្រមរដ្ឋប្បវេណីស្ថាពរលេខ:០១"គ",០២"គ",០៣"គ" ០៤"គ" និង ០៥"គ" ចុះថ្ងៃទី១៣-០១-១៩៩៥ របស់តុលាការខេត្តកណ្តាល តាមពាក្យសុំអនុវត្តសាលក្រមចុះថ្ងៃទី២៥-៨-២០០០ របស់ឈ្មោះឡា កាយ ។

៤-ទុកសិទ្ធិឱ្យឈ្មោះអ៊ួ មួន ប្តឹងជំទាស់តាមច្បាប់ ។

៥-សំរេចកាត់យកប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្លឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛ និងលើអាជ្ញាធរតុលាការ ៥.០០០៛ ។

៦-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខឈ្មោះឡា មីន តំណាងឱ្យឈ្មោះឡា កាយ និងចំពោះមុខឈ្មោះអ៊ួ មួន ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ២៩៤ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣ របស់ឈ្មោះឡា មីន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៦៧"ង"ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី២ នៃសាលដីកាដោយមូលហេតុចំណុចនេះសំរេចបដិសេធ

សាលក្រមរបស់តុលាការខេត្ត ។

បានឃើញបណ្តឹងសាទុក្ខលេខ ២៩៨ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៣ របស់ឈ្មោះ អ៊ូ មួន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៦៧"ង"ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី៤ និងទី ៣ នៃសាលដីកា ដោយមូលហេតុការអនុវត្តន៍សាលក្រមនេះធ្វើឱ្យចូលដីខ្លួន៥ម ។

បានឃើញសារណាការពារនិងតបចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៣របស់ឈ្មោះឡា មីន។

បានឃើញសារណាការពារនិងតបចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ របស់ឈ្មោះអ៊ូ មួន ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីលេខ ៦៧"ង"ចុះថ្ងៃទី១៦-៦-២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។ អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យនិងសំរេច ។

បានស្តាប់ចំលើយរបស់ឈ្មោះឡា មីន នាពេលសវនាការថា : បានជាខ្លួនប្តឹងសាទុក្ខពីសាលដីការបស់សាលាឧទ្ធរណ៍ មកពីសាលាឧទ្ធរណ៍បានបដិសេធសាលក្រម របស់តុលាការខេត្តកណ្តាលចោល ។ ខ្លួនសុំតំកល់សាលក្រមរបស់តុលាការខេត្តកណ្តាលទុកជាបានការ ។

បានស្តាប់ចម្លើយរបស់ឈ្មោះអ៊ូមួន នាពេលសវនាការថា :ខ្លួនប្តឹងសុំមិនឱ្យគេអនុវត្តសាលក្រម ខ្លួនមិនប្តឹងជំទាស់នឹងសាលដីការបស់សាលាឧទ្ធរណ៍ទេ សូមឱ្យអនុវត្តតាមសាលាឧទ្ធរណ៍ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកហាក់ សៀកលី មេធាវីចុងចម្លើយនា ពេលសវនាការថា : តុលាការថ្នាក់ក្រោមបានធ្វើសេចក្តីជូនដំណឹងពីការអនុវត្តន៍សាលក្រមចំនួន៥ លោកអ៊ូ មួន ប្តឹងជំទាស់ដោយថា គាត់មានសាលក្រមមួយជាន់លើដីនេះ តុលាការថ្នាក់ក្រោមបាន ទទួលស្គាល់សាលក្រមលេខ០១"គ",០២"គ",០៣"គ",០៤"គ" និង០៥"គ" ។ អង្គប្រជុំនៅក្រសួង យុត្តិធម៌ថ្ងៃទី២៥-៥-២០០១ យល់ថា សាលក្រមលេខ ២៧"រ" និង ២៨"រ" ធ្វើឡើងមិនប្រក្រតី ។ រឿងនេះជារឿងជំទាស់នឹងសាលក្រម វាស្រដៀងគ្នានឹងរឿងកិច្ចការប្រញាប់ បើសិនតុលាការកំពូលឱ្យអនុវត្តសាលក្រម ជារឿងត្រឹមត្រូវដែរ ។ សូមឯកឧត្តមប្រធានមេត្តាពិនិត្យពិចារណា រឿងនេះចូលជាស្ថាពរតាំងពីឆ្នាំ១៩៩៥ តែរហូតដល់ឆ្នាំ១៩៩៩ ទើបអនុវត្ត ។ សូមឯកឧត្តមប្រធាន មេត្តាពិចារណានិងតំកល់សាលក្រមរបស់តុលាការខេត្តកណ្តាល ដោយតុលាការគ្រប់ជាន់ថ្នាក់ទទួលស្គាល់សាលក្រមទាំង៥ ហើយដែរ ។ តុលាការខេត្តកណ្តាលលប់សាលក្រមនោះ ខ្លួនមិនដឹងទេ តែនេះជាការប្រជុំរបស់ក្រសួង ហើយធ្វើតាមការណែនាំរបស់ថ្នាក់លើ នេះគឺជានីតិក្រមថ្នាក់លើប្រជុំ ហើយនេះមកពីការធ្វេសប្រហែសរបស់ក្រឡាបញ្ជី ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកឈី សម្បត្តិ មេធាវីការពារឱ្យដើមចោទ បានលើកឡើងនាពេលសវនាការថា : កូនក្តីខ្លួនបានសំណូមពរហើយ ដោយសុំតំកល់សាលដីការបស់សាលាឧទ្ធរណ៍ ។ ខ្លួនមិនដឹងថា តើហេតុម្តេចបានជាតុលាការខេត្តកណ្តាលចេញសាលក្រមថ្មី លប់សាលក្រមចូលជាស្ថាពរចោលទេ ? សូមឯកឧត្តមប្រធានមេត្តាពិចារណាលើបញ្ហានេះ ។ សំណូមពរ : សុំតំកល់សាលដីកាលេខ ៦៧"ង"ចុះថ្ងៃទី១៦-៦-២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចំលើយគូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគី .
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៩៤ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣ របស់លោក ឡា មីន និងបណ្តឹងសាទុក្ខលេខ ២៩៨ ចុះថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០០៣ របស់លោក អ៊ូ មួន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ សំរេចបដិសេធសាលក្រមរដ្ឋប្បវេណីលេខ ៦១"ក" ចុះថ្ងៃទី២០-៨-២០០២ របស់តុលាការខេត្តកណ្តាលចោល ហើយបង្គាប់ឱ្យអនុវត្តសាលក្រមលេខ ០១"គ",០២"គ",០៣"គ",០៤"គ",និង ០៥"គ" ចុះថ្ងៃទី១៣-០១-១៩៩៥ និងទុកសិទ្ធិឱ្យឈ្មោះអ៊ូ មួន ប្តឹងជំទាស់តាមច្បាប់ដោយអាងលើលិខិតលេខ ២១ អគ្គ ២០០២ ចុះថ្ងៃទី ០៩-០១-២០០១ របស់ក្រសួងយុត្តិធម៌ និងបណ្តឹងជំទាស់នឹងការអនុវត្តសាលក្រមរបស់ដើមចោទមានលក្ខណៈជាការប្រញាប់នោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះលិខិតរបស់ក្រសួងយុត្តិធម៌ ពាក្យបណ្តឹងជំទាស់ចុះថ្ងៃទី២៩-១២-២០០១ របស់ដើមចោទ និងពាក្យបណ្តឹងរបស់ចុងចម្លើយចុះថ្ងៃទី ១២-៨-២០០២ ពុំមានខ្លឹមសារណាដែលតំរូវឱ្យសាលាឧទ្ធរណ៍សំរេចជាកិច្ចការប្រញាប់ផ្សេង និងឱ្យដើមចោទ ប្តឹងជារឿងអង្គសេចក្តីផ្សេងទេ ។ ម៉្យាងទៀតដើម្បីកុំឱ្យអូសបន្លាយពេលវេលា និងកុំឱ្យនីតិវិធីនេះ កាន់តែស្មុគ្រស្មាញឡើងក្នុងពេលដែលច្បាប់ស្តីពីការអនុវត្តសាលក្រម ពុំទាន់មានគ្រប់គ្រាន់ គប្បីសំរេចរឿងនេះដល់អង្គសេចក្តីតែម្តង ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៦៧"ង"ចុះថ្ងៃទី ១៦-៦-២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសុំរេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ២៩៤ ចុះថ្ងៃទី៣១-៧-២០០៣ របស់លោកឡា មីន និង បណ្តឹងសាទុក្ខលេខ ២៩៨ ចុះថ្ងៃទី០៤-៨-២០០៣ របស់លោកអ៊ូ មួន ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៦៧"ង"ចុះថ្ងៃទី១៦-៦-២០០៣ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋវេណីលេខ ៣៨៧ ចុះថ្ងៃទី១៥-៩-២០០៣របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន៣៨.០០០រដែលលោកឡា មីន បានបង់គឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្លឹងចំនួន៤.០០០រ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយលើការប្រគល់ដីកាកោះចំនួន ១៥.០០០រ សរុប ១៩.០០០រៀល នៅសល់១៩.០០០រ ប្រគល់ឱ្យលោកឡា មីន និងតម្រូវឱ្យលោកអ៊ូ មួន សងប្រាក់៩៥០០រៀល ទៅលោកឡា មីន វិញ ។

៥-សាលដីកានេះជំនុំជំរះនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និង ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៤ ។